សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០០៤
ចុះថ្ងៃទី០៤-០៨-២០២២
សាលដីកា
លេខ: ១២១ក្រ II -ន-
ចុះថ្ងៃទី៣១-១០-២០២២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាម ព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០-៨-២០០៧ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ភ្នំពេញថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ដោយមានសមាសភាព ដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ: ១០០៤ ចុះថ្ងៃទី០៤-០៨-២០២២ ដែលមាន៖

១-ជនជាប់ចោទឈ្មោះ[redacted]ចនា ហៅ សីហា ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិតាណ ឃុំតេជោ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។ អាសយដ្ឋានស្នាក់នៅផ្ទះ[redacted] កំបូល រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted] [redacted]មានកូន ១ នាក់ ឪពុកឈ្មោះ[redacted]"រ" ម្តាយឈ្មោះ[redacted] "រ" ទោសពីមុនគ្មាន (ក្នុងឃុំ)។ (ប្តឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩០៨ "ឃ" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

មានលោក[redacted]ស៊ីថាន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

២-ជនជាប់ចោទឈ្មោះ[redacted] វាសនា ហៅ ស្នា ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ អាសយដ្ឋានស្ន[redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ[redacted]គ្មានកូន ឪពុកឈ្មោះ[redacted]" ម្តាយឈ្មោះ[redacted] "រ" ទោសពីមុនគ្មាន ។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៧៩០៧ "ឃ" ដ.ឃ.ដ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ។

ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ





Scanned with CamScanner

ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១២០៤ "យ" ដ.ជ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

-ជនរងគ្រោះឈ្មោះ[redacted]ហឿត ភេទស្រី អាយុ ៣៧ ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានទៅផ្ទះលេខ៧ ផ្លូវលេខ១២២ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២០ និង២០នាទី ជនជាប់ចោទឈ្មោះ វ័ត្ន រចនា និងជនជាប់ចោទឈ្មោះ[redacted]រាសនា បានជិះម៉ូតូមួយគ្រឿងម៉ាក វីវ៉ា ដើម្បីធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដោយជនជាប់ចោទឈ្មោះ[redacted]រចនា ជាអ្នកបើកម៉ូតូ និងជនជាប់ចោទឈ្មោះ[redacted]រាសនា ជិះនៅខាងក្រោយ។ ដល់ចំណុចកើតហេតុត្រង់ផ្លូវប្រសព្វស្តុបដេអិន ពេលឃើញជនរងគ្រោះកំពុងធ្វើដំណើរថ្មើរជើង ជនជាប់ចោទឈ្មោះ[redacted]រចនា បានជិះអែបទៅខាងស្តាំដៃរបស់ជនរងគ្រោះ ហើយជនជាប់ចោទឈ្មោះ[redacted]រាសនា បានធ្វើសកម្មភាពឆក់កាបូបស្ពាយ ដែលជនរងគ្រោះបានស្ពាយជាប់នឹងស្មា បណ្តាលឱ្យជនរងគ្រោះដួលទៅលើថ្នល់រងរបួសស្រាល។ ចំណែកជនជាប់ចោទទាំងពីរនាក់បានជិះម៉ូតូរត់គេចខ្លួនចេញពីកន្លែងកើតហេតុ ប៉ុន្តែជនជាប់ចោទត្រូវសមត្ថកិច្ច ដេញចាប់ឃាត់ខ្លួនបានភ្លាមៗ និងបានដកហូតកាបូបស្ពាយ ព្រមទាំងសម្ភារៈប្រគល់ឱ្យជនរងគ្រោះវិញ ។

-បានឃើញ: សាលក្រមព្រហ្មទណ្ឌលេខ: ៥០៣ "ក្រ.ស" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ[redacted]រចនា ហៅ សីហា ភេទប្រុស អាយុ ២៧ ឆ្នាំ និងឈ្មោះ [redacted]រាសនា ហៅ ស្នា ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៥ (ប្រាំ) ឆ្នាំ។

ពីបទ លួចមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ។

២-វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ២០៤០ វ.ប.ត ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ មានម៉ូតូម៉ាក SUZUKI VIVA ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CC- 7657 ចំនួន ១ គ្រឿង រឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ ។

-បានឃើញ: សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ៦៥០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ[redacted]រចនា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៥០៣ "ក្រ.ស" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ បស់



Scanned with CamScanner

សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

-បានឃើញ: របាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ ។

-បានឃើញ: សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted]ចនា (វត្តមាន)

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ [redacted]ស៊ីថាន (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]ចនា បានឆ្លើយថា៖ ខ្លួនប្តឹងឧទ្ធរណ៍ព្រោះទោសធ្ងន់ពេក ខ្លួនមិនបានធ្វើឱ្យជនរងគ្រោះរបួសទេ ខ្លួនបានប្រគល់កាបូបឱ្យជនរងគ្រោះវិញហើយ ។ ខ្លួនមានឪពុកចាស់ជរាត្រូវមើលថែ ។ ខ្លួនស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ។

<u>តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា</u>

ឆ្លងតាមការពិភាក្សាដេញដោល និងពិនិត្យសំណុំរឿង ឃើញថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមកំណត់ច្បាប់ ។ តំណាងមហាអយ្យការទទួលយកអង្គហេតុនេះ ជាអង្គហេតុមិនប្រែប្រួល ។ ជនជាប់ចោទឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួន ចំណែកជនរងគ្រោះក៏មិនបានរងរបួសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់អ្វីដែរ ដូចនេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោសដល់ជនជាប់ចោទចំនួន ០១ (មួយ) ឆ្នាំ ។

-លោក [redacted]ស៊ីថាន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោល និងពិនិត្យភស្តុតាងនានា ឃើញថាជនជាប់ចោទឆ្លើយសារភាពថាបានប្រព្រឹត្តដូចការចោទប្រកាន់ ។ ខ្លួនឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ដែលស្នើសុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោសដល់ជនជាប់ចោទរយៈពេល០១ (មួយ) ឆ្នាំ ដោយហេតុថាជនជាប់ចោទបានឆ្លើយសារភាព និងបច្ចុប្បន្នគាត់មានប្រពន្ធ កូន និងឪពុកចាស់ជរានៅក្នុងបន្ទុក ។ ខ្លួនស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ដោយអនុគ្រោះ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

<u>សាលាឧទ្ធរណ៍ភ្នំពេញ</u>

<u>យល់ឃើញថា</u>

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ៦៥០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] រចនា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៩០៣ "ក្រ.ស" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលា



Scanned with CamScanner

ដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ធ្វើឡើងក្នុងកំណត់ច្បាប់ ផ្អែកតាមមាត្រា ៣៧៥មាត្រា ៣៧៦ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានជាសមត្ថកិច្ច ។

២-នាពេលសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] រចនា បានឆ្លើយថា៖ ខ្លួនប្ដឹងឧទ្ធរណ៍ព្រោះទោសធ្ងន់ពេក ខ្លួនមិនបានធ្វើឱ្យជនរងគ្រោះរបួសទេ ខ្លួនបានប្រគល់កាបូបឱ្យជនរងគ្រោះវិញហើយ ។ ខ្លួនមានឪពុកចាស់ជរាត្រូវមើលថែ ។ ខ្លួនស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ។

៣-តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោល និងពិនិត្យសំណុំរឿងឃើញថា បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទ ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមកំណត់ច្បាប់ ។ តំណាងមហាអយ្យការទទួលយកអង្គហេតុនេះ ជាអង្គហេតុមិនប្រែប្រួល ។ ជនជាប់ចោទឆ្លើយសារភាពទទួលស្គាល់កំហុសរបស់ខ្លួន ចំណែកជនរងគ្រោះក៏មិនបានរងរបួសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់អ្វីដែរ ដូចនេះតំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោសដល់ជនជាប់ចោទចំនួន ០១ (មួយ) ឆ្នាំ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៤-លោក [redacted] ស៊ីថាន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ឆ្លងតាមការពិភាក្សាដេញដោល និងពិនិត្យភស្តុតាងនានា ឃើញថាជនជាប់ចោទឆ្លើយសារភាពថាបានប្រព្រឹត្តដូចការចោទប្រកាន់ ។ ខ្លួនឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ដែលស្នើសុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោសដល់ជនជាប់ចោទរយៈពេល០១ (មួយ) ឆ្នាំ ដោយហេតុថាជនជាប់ចោទបានឆ្លើយសារភាព និងបច្ចុប្បន្នគាត់មានប្រពន្ធកូន និងឪពុកចាស់ជរានៅក្នុងបន្ទុក ។ ខ្លួនស្នើសុំក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់ជនជាប់ចោទ ដោយអនុគ្រោះ ។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍នឹងពិចារណាចំពោះការលើកឡើងនេះ ។

៥-សកម្មភាពរបស់ជនជាប់ចោទជាទម្រង់មួយនៃអំពើដែលមានធាតុផ្សំនៃបទល្មើស និងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ដែលច្បាប់បានចែង និងតម្រូវឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានក្នុងសំអាងហេតុ នៃសាលក្រមព្រហ្មទណ្ឌលេខ: ៤០៣ "ក្រ៦ស" ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ បានឯកភាព ហេតុនេះសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ មិនលើកយកសំអាងហេតុដដែលនេះមកធ្វើការបញ្ជាក់ជាថ្មីទៀតទេ ។

៦-មានពិរុទ្ធភាពគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] រចនា ហៅ សីហា ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្លូវប្រសព្វស្តុបដេអិន ផ្លូវលេខ១២៨ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧-សាលក្រមព្រហ្មទណ្ឌលេខ: ៤០៣ "ក្រ៦ស" ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានី



Scanned with CamScanner

ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ ប៉ុន្តែជនជាប់ចោទបានឆ្លើយសារភាពទទួលស្គាល់កំហុស ហេតុនេះគប្បីសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ សម្រេចបន្ធូរបន្ថយទណ្ឌកម្មខ្លះដល់ជនជាប់ចោទរូបនេះ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ៦៥០ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោ[redacted]រចនា ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ: ៤០៣ "ក្រ១ស ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេច ត្រូវកែប្រែមកជាផ្តន្ទាទោសឈ្មោ[redacted] រចនា ហៅ សីហា (សាវតាដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៤ (បួន) ឆ្នាំ ៦ (ប្រាំមួយ) ខែវិញ ។

ចំណុចផ្សេងពីនេះនៃសេចក្តីសម្រេចត្រូវរក្សាទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]ចនា តាមច្បាប់ ។

សាលដីកានេះបានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ចនា និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ ។

ទុកសិទ្ធិប្តឹងសាទុក្ខក្នុងរយៈពេលដែលច្បាប់បានកំណត់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted], [redacted] | ហត្ថលេខា [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner